## ៥. ការគ្រប់គ្រងជំងឺ

នៅពេលដែលពិនិត្យឃើញមានជំងឺនេះ គេត្រូវធ្វើការព្យាបាលភ្លាមៗ ជំងឺនេះបំផ្លាញមែកខ្ចីនិងផ្នែកនៃដើមនៅត្រង់កន្លែងបែកមែកនិងធ្វើឲ្យខូចសំបកយ៉ាងឆាប់រហ័សហើយនិងអាចបណ្តាលឲ្យងាប់មែកនិងងាប់ចុងទាំងស្រុងទៀតផង។

ការព្យាបាលដោយជោគជ័យគឺអាស្រ័យលើការឆាប់ដឹងភ្លាមៗ ចាប់តាំងពីផ្សិតកើតដំបូង។ កាលណាផ្សិតកើតរុំជុំវិញមែករួចហើយមែកនឹងងាប់ **គេមិនអាចព្យាបាលវាបានទេ**។ ត្រូវព្យាបាលដោយបាញ់ថ្នាំសម្លាប់ផ្សិតលើមែកឈើ ដោយប្រើឧបករណ៍ដែលមានដងវែងនិងក្បាលបាញ់សាច។

ប្រសិនបើជំងឺធ្ងន់ធ្ងរ គឺត្រូវកាត់មែកដែលកើតជំងឺឲ្យដល់ផ្នែកខាងក្រោមដែលគ្មានជំងឺប្រវែង៣០ស.ម រួចយកទៅកប់ ឬដុតចោល។ ដើម្បីគ្រប់គ្រងជំងឺនេះ គេអាចបាញ់ថ្នាំសម្លាប់ផ្សិតដូចជា៖

-ល្បាយប័រដូ (Bordeaux Mixture) លើមែក ចំពោះដើម



ការបាញ់ថ្នាំ Validamycin



ឧបករណ៍ព្យាបាលជំងឺផ្កាកូលាប

កៅស៊ូ**មិនទាន់ចៀរជ័រ** ដែលត្រូវបាញ់ប្រវែង៣០-៥០ស.មផ្នែកខាងលើនិងខាងក្រោមកន្លែងដែលកើតជំងឺ។ ថ្នាំនេះហាមប្រើចំពោះដើមកៅស៊ូកំពុងចៀរជ័រ ព្រោះវាអាចធ្វើឲ្យប៉ះពាល់ដល់គុណភាពទឹកជ័រ។

- ទ្រីដឺម័ហ្វ (Tridemorph) នៅកំហាប់ 1%
- វ៉ាលីដាមីស៊ីន (Validamycin) នៅកំហាប់ 1.5% - 2%។

ការបាញ់ប្រព្រឹត្តទៅពី១០-១៤ថ្ងៃម្តង ហើយបាញ់ឲ្យបាន៣-៤ដងតាមភាពចាំបាច់ ចាប់ពីពេលកើតជំងឺ៕


**វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**

អាសយដ្ឋានៈ អគារលេខ ៩ មហាវិថី ប៉ែននុត (២៨៩) សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ឬ ប្រអប់សំបុត្រលេខ ១៣៣៧ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ៨៨២ ៨៣១

សារអេឡិចត្រូនិច : crri@camnet.com.kh

វិបសាយ : www.crri.com.kh



ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា



ប័ណ្ណបច្ចេកទេស ២០១៣/០១


# ជំងឺផ្កាកូលាប

# Pink disease




ការផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

ការិយាល័យដាំដុះនិងការពារ

## ១. លក្ខណៈទូទៅ

ជំងឺផ្កាកូលាប ជាជំងឺមួយដែលកើតនៅលើដើមនិងមែក ហើយមានឈ្មោះយោងទៅតាមពណ៌សម្បុរនៃរោគសញ្ញារបស់វា។ ជំងឺនេះរាលដាលពីសំបករូចចូលទៅក្នុងសាច់ឈើ។ វាចាប់ផ្ដើមរាតត្បាតភាគច្រើននៅត្រង់ប្រគាបមែក ព្រោះនៅកន្លែងនេះសំបកមានសំណើមជាប់យូរក្រស្ងួតក្រោយមេឃភ្លៀង។

## ២. ភ្នាក់ងារបង្កជំងឺ

ជំងឺនេះបណ្ដាលមកពីផ្សិត Corticium salmonicolor ។ ស្ព័ររបស់ផ្សិតនេះឆ្លងពីដើមមួយទៅដើមមួយទៀតដោយសារខ្យល់។ ជំងឺឆ្លងរាលដាលខ្លាំងនៅពេលអាកាសធាតុសើម នៅពេលផ្សិតបំភាយស្ព័រនិងផ្ទៃសំបកសើមល្មមធ្វើឲ្យស្ព័រលូតលាស់នឹងកកើតជាផ្សិតបាន។

វារាតត្បាតច្រើននៅពេលមានភ្លៀងធ្លាក់ជោគជាំ ពីខែកក្កដា, សីហា, កញ្ញា និងខែតុលា ហើយវាច្រើនកើតនៅលើដើមកៅស៊ូដែលមានអាយុពី ៣ ទៅ ១២ឆ្នាំ។



ជ័រហូរចេញនិងកកជាធ្លុតខ្មៅ

## ៣. ក្លូនងាយទទួលរងជំងឺ

ក្លូនដែលងាយរងជំងឺខ្លាំងមាន ក្លូន RRIM 600, PB 314, PB 217 និង PB 311 រីឯក្លូនដែលធន់ជំងឺមានក្លូន PB 260, GT1 និង PR 107 ។



ការប្រេះសំបក

## ៤. សញ្ញាជំងឺ

នៅត្រង់កន្លែងបែកមែកមានសរសៃប្រទាក់គ្នា (ដូចសំបុកពីងពាង) ជាមួយនឹងការចេញជ័រជាពិសេសនៅកន្លែងប្រគាបមែក បន្ទាប់មករាលដាលរុំជុំវិញមែកនិងមានពណ៌ផ្កាកូលាប ប្រសិនបើមិនបានព្យាបាលទាន់ពេលវេលា សំបកក៏ស្ងួតប្រេះហូរជ័រចេញក្រៅ ហើយកកជាធ្លុតខ្មៅ។



ប្រគាបមែកមានពណ៌ផ្កាកូលាប

អាស្រ័យដោយការស្ទះនៃចលនាទឹកជ័រឡើងទៅផ្នែកខាងលើ បណ្ដាលឲ្យមានដុះចេញនូវមែកថ្មីនៅខាងក្រោមនៃផ្នែកដែលមានកើតជំងឺ ចំណែកឯមែកដែលកើតជំងឺ ជ្រុះស្លឹក បន្ទាប់មកក្រៀមងាប់។



មែកថ្មីដុះចេញនៅខាងក្រោមនៃផ្នែកកើតជំងឺ